ឆ្នាំទី២ លេខ ០០៥ ខែកុម្ភៈ ឆ្នាំ ២០០៧ ទំព័រទី១

# អង្គការសកម្មភាពដើម្បីស្រាវជ្រាវ និងអភិវឌ្ឍន៍
# Action for Research and Development

សមត្ថភាព គុណភាព តម្លាភាព
Capacity Quality Transparency

ផ្ទះលេខ ៥១F ផ្លូវ ២៦៥ សង្កាត់ ទឹកល្អក់ ៣
ខណ្ឌទួលគោក ក្រុងភ្នំពេញ កម្ពុជា
ទូរសព្ទ័លេខ: ០១៦ ៧៧៨ ៧០១
អ៊ីម៉ែល: ard.cabodia@yahoo.com
ard.info@yahoo.com
ប្រអប់សំបុត្រ: CCC ៣០៤

# ពត៌មានសំខាន់សំរាប់អ្នក
# Necessary News for You

## ព្រឹត្តិបត្រពត៌មានប្រចាំខែ
## Monthly Newsletter

ចែកជូនដោយឥតគិតថ្លៃ

### មាតិកាពត៌មាន

- សិក្ខាកាមវគ្គការងារអភិវឌ្ឍន៍សហគមន៍ចំនួន ៤០ នាក់ បានបញ្ចប់............ ២
- ជំណឹងជ្រើសរើសបុគ្គលិក.............................................. ៣
- ជំងឺគ្រុនផ្តាសាយបក្សី បានកើតឡើងជាថ្មីនៅប្រទេសជិតខាងកម្ពុជា.............. ៥
- គំនិតខ្លះទាក់ទងនឹងការពង្រាបដីស្រែ និងគ្រប់គ្រងទឹក........................ ៦
- ត្រីរាជដែលជិតផុតពូជ រកឃើញទីជំរកនៅក្នុងទឹកទន្លេមេគង្គប្រទេសកម្ពុជា....... ៧
- ក្រលេកមើលការរស់នៅរបស់កុមារជនជាតិនៅប៉ៃលិនប្រទេសកម្ពុជា....... ៨
- ជំហានគំរូមួយដើម្បីលុបបំបាត់អំពើរំលោភសេពសន្ថវៈ........................ ៩
- សូមបោះឆ្នោតជូនប្រាសាទអង្គរវត្តជាអច្ឆរិយទាំង៧ ក្នុងពិភពលោក............. ១០

# កម្មវិធីរបស់ ARD

## សិក្ខាកាមវគ្គការងារអភិវឌ្ឍន៍ សហគមន៍ចំនួន ៤០ នាក់ បានបញ្ចប់ដោយជោគជ័យ

អង្គការសកម្មភាពដើម្បី ស្រាវជ្រាវ និងអភិវឌ្ឍន៍ (អេ អ ឌី) បានបើកវគ្គបណ្តុះបណ្តាលស្តីពីការងារអភិវឌ្ឍន៍សហគមន៍ ដែលមានរយៈពេល ៤០ ម៉ោង និងមានសិក្ខាកាមសរុបចំនួន ៤០នាក់ (ស្រី ១២នាក់) ដែលត្រូវបានជ្រើសរើសដោយស្មើភាព និងយុត្តិធម៌ មកពីមហាវិទ្យាល័យផ្សេងៗគ្នា។ វគ្គបណ្តុះបណ្តាលត្រូវបានរៀបចំឡើងនៅរៀងរាល់ថ្ងៃសៅរ៍ និងថ្ងៃអាទិត្យ ដែលមានរយៈពេល៤ម៉ោងក្នុងសប្តាហ៍។ ប្រធានបទសំខាន់ៗដែលលើកយកមកសិក្សារួមមាន :

- ទស្សនៈជាមូលដ្ឋានអំពីការងារអភិវឌ្ឍន៍ និងគោលការណ៍នៃការអភិវឌ្ឍន៍
- តួនាទី ការទទួលខុសត្រូវរបស់អ្នកអភិវឌ្ឍន៍សហគមន៍ និងគុណភាពនៃការធ្វើការងារអភិ-វឌ្ឍន៍សហគមន៍
- ដំណើរការរៀបចំសហគមន៍
- អំពីយេនឌ័រ និងទំនាក់ទំនងនៅក្នុងការងារអភិវឌ្ឍន៍សហគមន៍
- អំពីការវិភាគបញ្ហា និងវិភាគដំណោះស្រាយ
- ការធ្វើផែនការសកម្មភាព និងផែនការថវិកា
- ការសំរបសំរួល និងការធ្វើការ-ងារជាក្រុម
- ការត្រួតពិនិត្យ និងវាយតំលៃគំរោងអភិវឌ្ឍន៍

វគ្គបណ្តុះបណ្តាល ត្រូវបានអញ្ជើញចូលរួមសំរបសំរួល និងជាគណៈកម្មការវាយតំលៃរបាយការណ៍បញ្ចប់វគ្គ ដោយមន្ត្រី បុគ្គលិក ដែលមានបទពិសោធន៍ទាក់ទងនឹងការងារអភិវឌ្ឍន៍សហគមន៍ មកពីអង្គការជាតិ- អន្តរជាតិ ក្នុងនោះមាន :

- លោក សួន សុខេង នាយកប្រតិបត្តិអង្គការ ARD
- លោក ព្រំ ង៉ា អ្នកសំរបសំរួលប្រចាំប្រទេសកម្ពុជា នៃអង្គការ HEKS
- លោក ជឿន វិចិត្រ នាយកប្រតិបត្តិអង្គការ PDAO
- លោក យី គឹមថាន (អង្គការសេដាក់)
- លោក ឆាយ ទី (អង្គការ CelAgrid)
- លោក អៀច ធា (អង្គការស្បៀងអាហារពិភពលោក)
- លោក លី ប៊ុនថៃ ទីប្រឹក្សាគំរោង PLG/UNDP
- លោក ណៃ សុខលាង ស្ថាបនិកអង្គការ ARD
- លោក លី សុភា (អង្គការអុកស្វាមអង់គ្លេស)
- លោក គង់ វឌ្ឍា អ្នកសំរបសំរួលកម្មវិធីអង្គការ ARD

នៅចុងបញ្ចប់វគ្គ សិក្ខាកាមបានសរសេររបាយការណ៍បញ្ចប់វគ្គ ទៅលើប្រធានបទដូចខាងក្រោម :

- ការសិក្សាពីកម្មវិធីឡជីវឧស្ម័នរបស់អង្គការ CelAgrid
- ការសិក្សាអង្កេតពីកម្មវិធីចិញ្ចឹមមាន់ និងជន្លេន របស់អង្គការ CelAgrid
- ការសិក្សាអង្កេតពីកម្មវិធីចិញ្ចឹមជ្រូកជាលក្ខណៈគ្រួសារ ដែលគាំទ្រដោយអង្គការ CelAgrid
- ការសិក្សាអង្កេតពីដំណើរការក្រុមធនាគារស្រូវនៅភូមិពន់ចាន់ ស្រុក កណ្តាលស្ទឹង ខេត្តកណ្តាល របស់អង្គការ World Vision
- ការសិក្សាអង្កេតពីដំណើរការក្រុមសន្សំ នៅភូមិពន់ចាន់ ឃុំព្រែកស្លែង ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល របស់អង្គការ World Vision
- ការសិក្សាអង្កេតពីដំណើរការចងក្រងក្រុម កសិករគោលដៅ នៅភូមិខ្វារ ឃុំក្រាំងធ្នង់ ស្រុកបាទី ខេត្តតាកែវ អង្គការ PDAO
- ការសិក្សាអង្កេតពីការអនុវត្តន៍កម្មវិធីឥណទាន នៅភូមិខ្វារ ឃុំក្រាំងធ្នង់ ស្រុកបាទី ខេត្តតាកែវ របស់អង្គការ PDAO
- ការសិក្សាអង្កេតពីការអនុវត្តន៍កម្មវិធីអភិវឌ្ឍន៍កសិកម្ម នៅភូមិខ្វារ ឃុំក្រាំងធ្នង់ ស្រុកបាទី ខេត្តតាកែវ របស់អង្គការ PDAO ។

# ទំព័រឱកាសសំរាប់អ្នក

## Brief Job News

# ដំណឹងជ្រើសរើសបុគ្គលិក

| | |
|---|---|
| WVC | : National Advocacy Coordinator |
| NAA | : Technical Consultant |
| ARD | : Trainee |
| Wathnakpheap | : Rural Small Enterprise Assistants |
| UNDP/GEF | : Administration Assistant |
| CWCC | : Secretary General |
| VSO | : Many Positions |
| FHI | : Associate Director<br>Care and Treatment Officer |
| SOS | : Assistant Project Director |
| VBNK | : Trainer/Facilitator |

**World Vision Cambodia** is a Christian relief and development organization committed to working with poor communities, focusing on children, to transform lives and Cambodian society through sustainable development. We are looking for qualified Cambodian nationals to fill vacant position of **National Advocacy Coordinator** (Advocacy and Communication Department) based in Phnom Penh.
For job details and application please go to: http://www.worldvision.org.kh/news/joboppor.htm or contact our reception at #20, 71, Phnom Penh, Cambodia. Only short-listed candidates will be notified. Applications and CVs will not be returned.
***Women and disable people are encouraged to apply.***
***Deadline: February 19th, 2007***

---

Last year, the **National AIDS Authority** (NAA) developed the national strategy for advocacy that could help NAA members and civil society especially to the IEC working group to clearly understand the direction that HIV/AIDS advocacy could be implemented properly and successfully. With this developed strategy, the AC unit of the NAA need further step to work with the IEC technical working group to identify proper IEC material necessary to support the implementation of advocacy strategy specially focusing on OVC, MMP and HIV/AIDS law.

In doing this in a short period of time, the NAA need a **Technical Consultant** who could come for two months to help AC Unit of NAA to develop the need of IEC materials related to these four focused topics
Interest candidates can submit CV attached with related certificates and cover letter applying for at administration office not late than the closing date. Only short-listed candidates will be notified to come in for interview.
Address: # 226-232, Kampuchea Krom Blvd, Sangkat Mittapheak, Khan 7 Makara, Phnom Penh.
[*H/P: 016 904 206, Email: admin@naa.org.kh*

***Deadline: February 9th, 2007***

**Actions for Research and Development 'ARD'** have planned to conduct a new training course on **Development Project Management** which will take place in the two different groups:
1. Every Monday, Wednesday, Friday (15:00-17:00pm)
2. Every Saturday Morning (07:30-11:30 am)

The training will start on 03 March 2007 and facilitate by experience Facilitators/Trainers. The training course will conduct in the period of 40 hours. The trainees for this Training are **40** (**20 trainees each group**).
The course will cover in the following topic:
- The definition and type of Development Project
- Development Project Cycle
- Problem Analysis, Problem Tree, Objective Tree and Solution
- Project Planning (Activity Plan, Budget Plan)
- Project Logical Frame Work
- Project Monitoring and Evaluation
- Orientation on Project Proposal Writing

All students and young graduates from various Universities who interested this subject and **have available time as the date mentioned above** are invited to apply for participating this training course by sending **an updated CV with a current photo and a Letter of Interest** by specifying the Training Group (**Group 1 or Group 2**) to ARD office: house # 51F, St 265, Teuk Laak3, Tuol Kuok, Phnom Penh. For more information please contact through phone number 016 77 87 01.
**Note:**
- **No any applications by email will received.**
- **The successful candidates have to contribute a small fee for the training course.**

***Deadline: February 23, 2007***

---

**WATHNAKPHEAP**, Cambodian NGO supporting disadvantaged children and their families through its Community-Based Child Development Programme in Pursat since 1993 and in Svay Rieng in late 2004 and in Siem Reap in 2005. WATHNAKPHEAP Siem Reap is seeking for 3 full time positions as **Rural Small Enterprise Assistants** (2 positions are community-based, and one is Marketing) as following to be based in Chikreng District, Siem Reap Province.

Interested and qualified candidates should send only a detailed CV with Cover letter and other relevant documents to WP Governing Board.
No direct approaches to WATHNAKPHEAP office or employees will be excepted and may result in disqualification of the application. Only short listed candidates will be invited for interview.
Address: CCC: P.O. Box 90, Tel: 099 919 166; Email: wp@online.com.kh, wpsiemreap@camshin.com.kh

***Deadline: February 7th, 2007***

# ទំព័រឱកាសសំរាប់អ្នក

## Brief Job News Continue....

# ដំណឹងជ្រើសរើសបុគ្គលិក

**The UNDP/GEF** - supported project "Enabling Activities for the Preparation of the 2nd National Communication to the UNFCCC" invites suitable national candidates to apply for the position **Administration Assistant**, which is based at the Ministry of Environment, Phnom Penh.
Interest Candidate please send your application letter, CV and, if available, UN Personnel History Form (P11) by e-mail to etap@online.com.kh or to Climate Change Office at the Ministry of Environment, #48, Samdech Preah Sihanouk Blvd, 2nd Floor, Room 303B, Phnom Penh. Only short-listed candidates will be contacted. CV will not be returned.
***Deadline: February 10th, 2007***

---

**The Cambodian Women's Crisis Center (CWCC)** is a non-governmental organization founded and registered with the Ministry of Interior in Phnom Penh in 1997 by a group of women who envisioned the outcry of women and children from gender-based abuses such as trafficking, rape, and domestic violence in addition to the suffering from the consequences of war. CWCC needs a qualified female candidate to fill the position of **Secretary General**.
Interested candidates are invited to send their applications via email or to the CWCC office at # 42 F, Street 488, Sangkat Psar Doeum Thkauv, Khan Chamkarmon, Email: <cwccpnp@citylink.com.kh>, <cwccpp@gmail.com>

***Deadline: February 6th, 2007***

---

**Voluntary Service Overseas (VSO)** is an international non-governmental organization that works through volunteers to fight global poverty and injustice. The Programme focus is implements in the quality, accessibility and relevance of basic education in six target provinces in Cambodia, focusing on the inclusion of girls, children with disability and other marginalized groups. We are looking candidate for following position:

- **Office Administrator** to support our office team and international volunteers working in Cambodia.
- **Education Programme Officer**
  This is a re-advertisement and previous candidates need not re-apply
- **Education Programme Assistant**

For further details about the job and how to apply. Please e-mail to vso.cambodia@vsoint.org.kh. Only short-listed applicants will be notified for an interview.
VSO Cambodia is committed to valuing difference and promoting diversity. Appointments are made solely on the basis of relevant skills and experience and not on the basis of Gender, Ethnicity, Disability, Sexuality, HIV/AIDS status, Age or Religion.
***Deadline: Thursday 15th February 2007 at 12pm***

**Family Health International (FHI)** in Cambodia works in partnership with government and non-governmental organizations to prevent HIV/STI transmission and mitigate the impact of HIV/AIDS on people's lives. FHI is urgently recruiting Cambodian nationals to fill in the position of

- **Associate Director**, Program Management based in Phnom Penh.
- **Care and Treatment Officer** based in Kampong Cham province.

Interest applicant please send CV and letter of application explaining your specific qualifications for the position via email: *<e-mail: sreytochn@fhi.org.kh>*, or to FHI Office at #11, Street 302, Boeung Keng Kang I, Chamkarmon, Phnom Penh *(Att: Ms. Nhim Sreytoch)*. Only applicants who are short listed for interview will be notified.

***Deadline: February 5, 2007***

---

**SOS Children's Villages** of Cambodia is a Local NGO, who has a MOU with the Ministry of Social Affairs, Veterans, and Youth Rehabilitation (MOSVY). SOS Children's Villages re-creates a Family for children who have lost their parents or are homeless for other reasons. The SOS Children's Village provides a permanent Home and a Family for children. Now we're looking for a **Assistant Project Director**
Interested candidates, Females are encouraged, who have experience and skills that fit the above required positions, please submit CV with a Covering Letter and a photograph to our office address in Phnom Penh not later than the closing date.
House No. 16 D, Street 360, Sangkat Boeung Keng Kang 3, Khan Chamkarmon, Phnom Penh
Tel. 023 222 915 (Fax), 023 222 916 (Office)
***Deadline: 28-Feb-2007***

---

**VBNK** is an established NGO offering training and facilitation services to the social development sector in Cambodia, while at the same time developing Cambodian capacity to deliver these services.
VBNK is seeking to recruit a Cambodian National for the position of **"Trainer/Facilitator".**
Applicants should have a strong understanding of and commitment to gender equity, values and ethics.
Full job description and application form for this position is available from the receptionist at VBNK (office@vbnk.org). Please send CV and application form to Administration Manager. No application will be considered without a completed VBNK application form. Address: VBNK, #28, St. 80 (near Calmette Hospital), Phnom Penh. Tel: 023 722115/116. http://www.vbnk.org

***Deadline: February 3rd, 2007***

# កសិកម្ម និងការអភិវឌ្ឍន៍

## ជំងឺគ្រុនផ្ដាសាយបក្សី បាន កើតឡើងជាថ្មីនៅប្រទេស ជិតខាងកម្ពុជា

ជំងឺគ្រុនផ្ដាសាយបក្សី គឺជាជំងឺ ដ៏កាចសាហាវមួយនាពេលបច្ចុប្បន្ននេះ ដែលមិនត្រឹមតែធ្វើស្លាប់មាន់ទា និងបក្សីផ្សេងទៀតឡើយ សូម្បីតែមនុស្សក៏ទទួលរងគ្រោះដោយសារជំងឺនេះដែរ។ ដោយសារជំងឺនេះ ដែលបានផ្ទុះឡើងនាចុងឆ្នាំ ២០០៣ រហូតដល់ចុងឆ្នាំ២០០៦ បានធ្វើអោយមនុស្សរាប់រយនាក់ បក្សីរាប់រយពាន់ក្បាលត្រូវស្លាប់ ដែលធ្វើអោយខាតបង់សេដ្ឋកិច្ចជាតិរាប់ពាន់លានដុល្លានៅក្នុងទ្វីបអាស៊ី ជាពិសេសប្រទេសឥណ្ឌូនេស៊ី វៀតណាម ថៃ កម្ពុជា។

នៅមួយរយៈចុងឆ្នាំ២០០៦នេះ ជំងឺផ្ដាសាយបក្សីបានស្ងប់ស្ងាត់មិនបង្កជាការព្រួយបារម្ភទៀតឡើយ។ ប៉ុន្តែស្រាប់តែនាពេលថ្មីៗនេះ ជាពិសេសក្នុងកំឡុងពេលខែធ្នូ ចុងឆ្នាំ២០០៦ និងខែមករា ដើមឆ្នាំ២០០៧ ជំងឺនេះបានផ្ទុះឡើងវិញ នៅប្រទេសជិតខាងកម្ពុជាមួយចំនួន គឺប្រទេសឥណ្ឌូនេស៊ី វៀតណាម និងថៃ។

ដោយឡែកនៅប្រទេសវៀតណាម ដែលស្ថិតនៅជាប់ខាងប្រទេសកម្ពុជាយើង បើយោងតាមកាសែតរស្មីកម្ពុជា ចេញផ្សាយថ្ងៃ៩មករា ឆ្នាំ២០០៧ បានអោយដឹងថា ជំងឺផ្ដាសាយបក្សីបានផ្ទុះឡើងក្នុងខែ១២នៅលើសត្វទា២៥ឃុំ ដែលបណ្ដាលត្រូវសំលាប់សត្វមាន់ទារហូតជិត២៤.០០០ក្បាល។

ក្រុមមន្ត្រីឱ្យដឹងថា គេក៏បានរកឃើញជំងឺកាលពីដើមខែធ្នូ ពេលត្រួតពិនិត្យទាដែលពុំទាន់បានចាក់វ៉ាក់សាំងនៅក្វាងណាម ។

អនុប្រធាននាយកដ្ឋានពេទ្យសត្វ លោកហ័ង វ៉ាន់ណាំ ថ្លែងប្រាប់ AFPថា "យើងខ្ញុំព្រួយបារម្ភណាស់ទៅដល់លទ្ធផលវិភាគនៅក្វាងណាម ហើយយើងខ្ញុំនឹងធ្វើវិភាគបន្ថែមទៀត " ។

លោកណាំឱ្យដឹងថា នាយកដ្ឋានពេទ្យសត្វ បានផ្សព្វផ្សាយសភាពការណ៍ប្រកាសអាសន្ននៅខេត្ត៥បន្ថែមទៀត នៅភាគកណ្ដាល និងខាងជើង ។

តំណាងFAO នៅវៀតណាម លោក Andrew Speedy ឱ្យដឹងថាអង្គការនេះកំពុងតាមដានយ៉ាងម៉ត់ចត់ និងយកគំរូវីរុស នាំទៅវិភាគបន្ថែម តែមិនចាំបាច់ត្រូវខ្លាចទេ។

"ទំនងជាការចាក់វ៉ាក់សាំងកំពុងត្រូវបានអនុវត្តល្អ ហើយរដ្ឋាភិបាលបានធ្វើគ្រប់យ៉ាង តាមដែលអាចធ្វើបានដើម្បីរាំងទប់ជំងឺ ហើយគេនៅតែកំពុងបន្តយុទ្ធនាការចាក់វ៉ាក់សាំងក្នុងប៉ុន្មានសប្ដាហ៍កន្លងទៅ ចាប់ពីពេលជំងឺផ្ទុះឡើងជាថ្មី អាជ្ញាធរបានចាក់វ៉ាក់សាំងឱ្យមាន់ទាចំនួន៧០០.០០០ក្បាល" ។

FAO ព្រមានថាគ្រោះឆ្លងជំងឺផ្ដាសាយបក្សីនឹងឡើង និងឡើងខ្ពស់ក្នុងបណ្ដាលខែត្រជាក់ និងក្នុងឱកាសចូលឆ្នាំ ព្រោះតំរូវការប្រើប្រាស់មាន់ទាកើនឡើង។

នាយកដ្ឋានពេទ្យសត្វ ក៏ព្រមានថា ជំងឺនេះនឹងកើតមានជាថ្មីនៅទីកន្លែងផ្សេងទៀតជាច្រើន ពិសេសនៅបណ្ដាលខេត្តភាគខាងជើង កន្លែងដែលមិនអាចត្រួតត្រាបានពីប្រភពរបស់បសុសត្វ ដែលត្រូវបានដឹកជញ្ជូនទៅលក់លើទីផ្សារ ។

កាលពីថ្ងៃ៣១ ធ្នូ ២០០៦ នាយករដ្ឋមន្ត្រី ង្វៀង តឹនយុង ក្នុងកិច្ចប្រជុំមួយជាមួយអាជ្ញាធររបស់ខេត្តខាងភាគខាងលិចចំនួន៧ បានសំណូមពរឱ្យមានវិធានការខ្លាំងក្លា ដើម្បីទប់ស្កាត់ជំងឺដែលបានផ្ទុះឡើងជាថ្មីនេះ។ លោក យុង បានសង្កត់ធ្ងន់ជាពិសេសដល់តំរូវការចាក់វ៉ាក់សាំង ឱ្យមាន់ទាដែលទើបញាស់។ នាយករដ្ឋមន្ត្រីអំពាវនាវអោយតំបន់ទាំងអស់បើកវគ្គផ្សព្វផ្សាយក្នុងស្រទាប់ប្រជាជន និងសន្យាថារដ្ឋាភិបាលនឹងជួយឧបត្ថម្ភដល់ការបង្ការប្រឆាំងជំងឺនៅខេត្តទាំង៧នេះ។

**នេះជាការប្រកាសអាសន្នមួយ ដែលធ្វើអោយប្រទេសកម្ពុជាយើង មានការព្រួយបារម្ភ និងប្រឹងប្រែងចាត់វិធានការទប់ស្កាត់ មិនអោយជំងឺផ្ដាសាយបក្សីកើតមានជាថ្មីនៅលើទឹកដីរបស់យើង។ អ្វីដែលសំខាន់ចំពោះមុខនោះ សូមប្រជាពលរដ្ឋមេត្តាយកចិត្តទុកដាក់ កុំប៉ះពាល់ រឺហូបបក្សីដែលសង្ស័យកើតមានជំងឺនេះ។**

# កសិកម្ម និងការអភិវឌ្ឍន៍

## គំនិតខ្លះទាក់ទងនឹងការពង្រាបដីស្រែ និងគ្រប់គ្រងទឹក

ការធ្វើស្រែជាមុខរបរមួយ យ៉ាងសំខាន់សំរាប់កសិករខ្មែរគ្រប់គ្នា ក្នុងការប្រកបរបរចិញ្ចឹមជីវិត។ ប្រជាកសិករតែងតែប្រាថ្នាចង់បានទិន្នផលស្រូវខ្ពស់គ្រប់ៗគ្នា ប៉ុន្តែភាគច្រើនមិនសូវបានដូចបំណងទេ តើហេតុអ្វី? ការពឹងផ្អែកទៅលើការលូតលាស់របស់ស្រូវតាមធម្មជាតិវា វារឿងមួយយ៉ាងសំខាន់ តែការធ្វើឱ្យប្រសើរឡើងដល់ប្រព័ន្ធលូតលាស់របស់ស្រូវ រឹតតែសំខាន់ថែមទៀត តាមរយៈការជួយជ្រោមជ្រែងពីមនុស្ស។ ដើម្បីចូលរួមនៅក្នុងការលើកស្ទួយទិន្នផលស្រូវសំរាប់កសិករខ្មែរ ពតិមានសំខាន់សំរាប់អ្នក សូមលើកយកនូវអត្ថបទរបស់លោក លឹម សុគន្ធដារុន ដែលបានចុះផ្សាយនៅក្នុងកាសែតកោះសន្តិភាព ថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៦ ដែលមានដូចខាងក្រោម :

តាមលទ្ធផល នៃការស្រាវជ្រាវឃើញថា បើសិនជាយើងគ្រប់គ្រងទឹកបានល្អ តាមតម្រូវការពិតប្រាកដរបស់ស្រុវ អាចជួយបង្កើនទិន្នផលស្រូវពី២០ ទៅ ៣០ ភាគរយ នៃផលស្រូវដែលទទួលបានកន្លងមក។ ឧទាហរណ៍ ពីមុនធ្វើស្រែលើដីមួយហិចតា ទទួលបានផល ១០០ថាំង តែបើសិនគេអាចគ្រប់គ្រងទឹកបានល្អ អាចកើនបានរហូតដល់ ១២០ ទៅ ១៣០ថាំង។ ផ្ទុយទៅវិញ បើសិនជាយើងមិនអាចគ្រប់គ្រងទឹកបានលើសពី៥០ ភាគរយនោះទេ ផលស្រូវរបស់យើង ក៏ថយចុះអាចរហូតដល់មិនបានច្រូតទៀផង ជាពិសេសនៅពេលស្រូវចាប់ធ្វើខ្លួន រហូតដល់ដំណាក់កាលស្រូវដាក់ទឹកដោះ។ នៅពេលច្រូត បើមានទឹកច្រើនពេក អាចធ្វើឱ្យប៉ះពាល់ទៅដល់គុណភាពគ្រាប់អង្ករទៀតផង។

**តើធ្វើយ៉ាងណា ដើម្បីគ្រប់គ្រងទឹកបាន ?**

១. ការលើកភ្លឺស្រែឱ្យបានខ្ពស់ និងរឹងមាំល្អអាចជួយទៅដល់ការគ្រប់គ្រងទឹក បានតាមសេចក្តីត្រូវការរបស់យើង ជាពិសេសនៅក្នុងតំបន់ដែលមានប្រព័ន្ធស្រោចស្រព។ យើងអាចធ្វើការបញ្ចេញបញ្ចូលទឹក តាមសេចក្តីត្រូវការរបស់យើង និងជួយរក្សាជីជាតិដីក្នុងស្រែកុំឱ្យបាត់បង់ថែមទៀត។

២. ការកៀរពង្រាបដីស្រែឱ្យស្មើរ វាអាចជួយនាំទឹក និងជីជាតិបានទៅដល់គ្រប់កន្លែងនៃស្រែរបស់យើងទាំងអស់ និងជួយឱ្យស្រូវលូតលាស់បានល្អស្មើៗគ្នា។ ជាការល្អ យើងអាចបែងចែកស្រែរបស់យើង ជាអំពកត្រូវល្មមតាមសណ្ឋានរបស់ដីខ្ពស់ ឬទាបដើម្បីងាយស្រួលកៀរពង្រាបដី និងគ្រប់គ្រងទឹក ហើយនៅក្បែរភ្លឺនីមួយៗ យើងត្រូវបង្កើតប្រឡាយនាំទឹកពីប្រភពទឹក ដែលយើងអាចទទួលបាន សំរាប់ឱ្យទឹកអាចចូលសព្វស្រែបានយ៉ាងរហ័ស និងពេញដំណាលគ្នា ។

៣. បើសិនជាមានលទ្ធភាព នៅតាមស្រែនីមួយៗ គួរតែមានកូនស្រះ និងប្រឡាយជីកព័ទ្ធជុំវិញ ដើម្បីស្តុកទឹកទុកជួយសង្គ្រោះស្រូវនៅពេលជួបប្រទះ ភាពរាំងស្ងួត ជាពិសេសនៅពេលមានកូនរដូវប្រាំងក្នុងរដូវវស្សា ពីពាក់កណ្តាលខែកក្កដាដល់ពាក់កណ្តាលខែសីហា។

នេះជាបទពិសោធន៏មួយ ដែលកសិករអាចអនុវត្តតាម ទាក់ទងនឹងការគ្រប់គ្រងទឹកអោយបានល្អ ដើម្បីជាប្រយោជន៏សំរាប់ការលូតលាស់របស់ដំណាំស្រូវ ដែលឈានទៅដល់ការផ្តល់ទិន្នផលខ្ពស់។ នៅប្រទេសកម្ពុជាយើង វិស័យកសិកម្ម ត្រូវបានលើកតំកើងជាអាទិភាពសំរាប់ការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ ដោយសារតែប្រជាពលរដ្ឋប្រមាណជា៨០ភាគរយរស់នៅជនបទ និងប្រកបរបរកសិកម្ម។ យោងទៅតាមសណ្ឋានដី និងលក្ខណៈអាកាសធាតុរបស់ព្រះរាជាណាចក្រកម្ពុជា គឺវាអំណោយផលយ៉ាងល្អដល់ការធ្វើកសិកម្ម ប៉ុន្តែបញ្ហាដែលកំពុងតែប្រឈមនាពេលបច្ចុប្បន្ន គឺចំណេះដឹងបច្ចេកទេស និងប្រព័ន្ធស្រោចស្រព ដែលកសិករខ្មែរយើងបាន និងកំពុងជួបប្រទះ ហើយនឹងត្រូវការជំនួយជាចាំបាច់។

ពតិមានសំខាន់សំរាប់អ្នក នឹងរីករាយទទួលយកនូវចំណេះដឹង បទពិសោធន៏ល្អៗនានា ដើម្បីធ្វើការផ្ទេរបន្តដល់កសិករខ្មែរយើងសំដៅធ្វើអោយមានភាពប្រសើរឡើងនូវការធ្វើកសិកម្ម។

# ទំព័រធនធានធម្មជាតិ និងបរិស្ថាន

## ត្រីរាជដែលជិតផុតពូជ រកឃើញទីជំរកនៅក្នុងទឹកទន្លេមេគង្គប្រទេសកម្ពុជា

តាមការចេញផ្សាយរបស់ កាសែត Cambodia Daily ថ្ងៃទី ០៦ ខែធ្នូ ឆ្នាំ២០០៧ បានអោយដឹងថា មានត្រីដែលមានទំហំដ៏ធំ បានហែលនៅក្នុងទឹកទន្លេមេគង្គក្នុងខេត្តស្ទឹងត្រែង ដែលមានចំងាយតែពីរបីរយម៉ែត្រប៉ុណ្ណោះពីប្រទេសឡាវ អស់រយៈពេលជាច្រើនឆ្នាំមកហើយ ។

ត្រីដ៏ធំនេះ ដែលបានធ្វើឱ្យប៉ូលីសភ័យខ្លាច គឺជាប្រភេទត្រីរាជដ៏ធំនៅក្នុងទន្លេមេគង្គ ឬ Pangasiamodon gigas ដែលថ្មីៗស្ថិតក្នុងពាក់កណ្តាលនៃដំណើរផ្លាស់ប្តូជំរកប្រចាំឆ្នាំរបស់វា ពីបឹងទន្លេសាបទៅទន្លេមេគង្គ ។

ជាសត្វរស់នៅក្នុងប្រទេសកម្ពុជា ប្រទេសឡាវ និងប្រទេសថៃ ត្រីរាជនេះគឺជាត្រីទឹកសាបធំបំផុតនៅក្នុងពិភពលោក ដែលមានប្រវែងដល់ទៅ២.៧ម៉ែត្រ និងមានទំងន់ជាង២៥០គីឡូក្រាម និងជាត្រីដែលមិនបង្កគ្រោះថ្នាក់ ជាប្រភេទត្រីគ្មានធ្មេញ ស៊ីតែស្លែ។

លោកZeb Hogan អ្នកជំនាញត្រីរាជ និងជាសាស្ត្រចារ្យស្រាវជ្រាវនៅសាកលវិទ្យាល័យ Nevada នៅ Reno នៃសហរដ្ឋអាមេរិកបានសរសេរ នៅក្នុងអ៊ីម៉ែលថា មានត្រីរាជធំពេញវ័យប្រហែល ១.០០០ក្បាលតែប៉ុណ្ណោះ ដែលនៅសល់ហើយភាគច្រើន ត្រូវបានរកឃើញនៅក្នុងប្រទេសកម្ពុជា។ ត្រីរាជនេះត្រូវបានចុះក្នុងបញ្ជី ជាត្រីជិតផុតពូជដោយសហគមន៍អភិរក្សពិភពលោក ។លោក ស្រ៊ុន លឹមសុង បានថ្លែងថា មធ្យោបាយសំខាន់ក្នុងកិច្ចការពារ និងស្រាវជ្រាវត្រីរាជរបស់កម្ពុជានេះ គឺការបិទផ្លាក ។

លោក ណៅ ធួក ប្រធានរដ្ឋបាលជលផល បានថ្លែងថានាយកដ្ឋានរបស់លោក បានតាមដានការចាប់ត្រីរាជ នៅទូទាំងប្រទេសដោយប្រញាប់ប្រញាល់ទៅកន្លែងមានការចាប់នោះ ដើម្បីត្រួតពិនិត្យ និងដោះលែងត្រីដ៏ធំនេះ។ លោកបានបន្ថែមថា រាល់ការចាប់ត្រីរាជទាំងអស់ត្រូវបានកើនឡើងអំឡុងរដូវបំលាស់ទី ក្នុងខែវិច្ឆិកា និងខែធ្នូ។ លោកបានថ្លែងថា រាល់ការចាប់ត្រីរាជទាំងអស់ យើងចាប់ត្រីនេះជាង១០ក្បាលក្នុង១ឆ្នាំ យើងបានបិទផ្លាក និងលែងទៅវិញជាង៤០ក្បាល។

លោក ស្រ៊ុន លឹមសុង បានមានប្រសាសន៍ថា ប្រវែងត្រូវបានវាស់ និងត្រីត្រូវបានថ្លឹង។ មន្ត្រីជលផលបានថ្លឹងត្រីទាំងនេះដើម្បីធ្វើការសន្និដ្ឋានទំងន់ តាមរយៈប្រវែង។

បំណែកតូចៗនៃព្រុយទ្រូង ត្រូវបានគេកាត់ចេញសំរាប់ការវិភាគពូជ ផ្លាកពណ៌បៃតងភ្លឺត្រូវបានបិទលើព្រុយខ្នង ហើយលេខផ្លាកត្រូវបានដាក់ចូលទៅក្នុងទិន្នន័យ ។

លោក ស្រ៊ុន លឹមសុង បានមានប្រសាសន៍ថា មកដល់ថ្ងៃនេះត្រីរាជទាំងអស់ដែលត្រូវបានពិសោធន៍នៅក្នុងប្រទេសកម្ពុជាមានពូជសុទ្ធ។ ប៉ុន្តែលោក Hogan បានគូសបញ្ជាក់ថា នៅប្រទេសថៃ ត្រីរាជយក្សនេះត្រូវបានគេភ្ញាស់ជាមួយប្រភេទត្រីដទៃទៀត ដែលមានលក្ខណៈស្រដៀងៗគ្នា គឺត្រី Pangasianodon Hypophthalmus ។

លោក ស្រ៊ុន លឹមសុង បានមានប្រសាសន៍ថាប្រសិនបើអ្នកនេសាទចាប់បានត្រី ដែលត្រូវបានពាក់ស្លាកនេះ ឬប្រភេទមច្ឆាទាំងឡាយជាង៤.០០០ក្បាលដែលត្រូវបានដាក់សញ្ញាដូច្នេះ គាត់អាចយកផ្លាកនេះទៅប្រគល់ឱ្យមន្ត្រីជលផលនៅក្នុងស្រុករបស់គាត់ ហើយគាត់នឹងទទួលប្រាក់រង្វាន់ជាង១.២៥ដុល្លារ ។

ត្រីរាជ៧ក្បាលត្រូវបានចាប់រហូតមកដល់ឆ្នាំនេះ។ ប៉ុន្តែនៅក្នុងប៉ុន្មានសប្តាហ៍ថ្មីៗនេះ ត្រីមួយក្បាលបានងាប់ពីរបីថ្ងៃក្រោយត្រូវបានបិទស្លាក និងត្រីដ៏ទៃទៀតបានងាប់ដោយថប់ដង្ហើមនៅសំណាញ់ដែលគេប្រើសំរាប់ស្រាវជ្រាវនេះ។ លោក ស្រ៊ុន លឹមសុង បានថ្លែងថា ឥឡូវនេះក្រុមអ្នកស្រាវជ្រាវបានសិក្សាស្វែងយល់ពីលក្ខណៈរបស់ត្រីរាជដោយមិនប្រថុយបិតផ្លាកគ្រប់ត្រីទាំងអស់ឡើយ។

**ដើម្បីចូលរួមអភិរក្ស និងរក្សាអោយបានពូជត្រីរាជសំរាប់កូនចៅជំនាន់ក្រោយ សូមប្រជាពលរដ្ឋទាំងអស់កុំនេសាទត្រីប្រភេទនេះ ហើយបើបានជួបវាសូមរាយការណ៍ជូនអជ្ញាធរមានសមត្ថកិច្ច។**

# ជីវិត និងសង្គម

## ក្រលេកមើលការរស់នៅរបស់កុមារជនជាតិនៅប៉ែកឦសាន ប្រទេសកម្ពុជា

កុមារជនជាតិព្នងពីរនាក់បងប្អូន រួមជាមួយម្តាយរបស់គេផង បានធ្វើដំណើរយ៉ាងស្វាហាប់ ដោយមានស្ពាយកាផាដាក់បន្លែព្រៃ និងបន្លែដាំយកទៅលក់នៅទីផ្សារសែនមនោរម្យ ទីរួមខេត្តមណ្ឌលគិរី នាព្រឹកព្រលឹម។ សកម្មភាពនេះ ត្រូវបានកុមារទាំងពីរនាក់ និងម្តាយជាជនជាតិព្នងទាំង៣នាក់និយាយថា បើហ៊ានផ្អាកប្រាកដជាដាច់បាយជាពុំខាន (នេះបើតាមការចុះផ្សាយរបស់កាសែតរស្មីកម្ពុជា ចេញថ្ងៃទី ២១ ខែវិច្ឆិកា ឆ្នាំ២០០៦)។

ដោយពេញចិត្ត និងដាក់ឈ្មោះជាខ្មែរ ស្ត្រីឈ្មោះកែវ លី អាយុ ២៧ឆ្នាំ ជាម្តាយនិយាយថា ឈ្មោះគាត់ដូចឈ្មោះប្តីដែរ។ ប្តីគាត់ជាទាហានពិការ ហើយសព្វថ្ងៃនេះ រស់នៅភូមិង៉ាកែ ឃុំរម្យនា ស្រុកសែនមនោរម្យ ខេត្តមណ្ឌលគិរី មុខរបរប្រចាំថ្ងៃធ្វើចម្ការលើផ្ទៃដីត្រឹមទំហំ ៦០ ម៉ែត្រ គុណ៦០ ម៉ែត្រ និងចូលព្រៃរកបេះបន្លែផ្លែឈើព្រៃ។ ផលិផលបន្លែបង្ការទាំងពីរមុខនេះនឹងត្រូវនាំទៅលក់នៅតាមផ្ទះប្រជាជន និងផ្សារនៅទីរួមខេត្ត ពោលគឺមានចម្ងាយជិត៧គីឡូម៉ែត្រ ពីទីស្ថានរបស់ពួកគាត់។

បើតាមស្ត្រីជនជាតិព្នងរូបនេះនិយាយថា បើគិតពីជីវិតគ្រួសារដែលមានប្តីពិការគឺវាលំបាកណាស់ទៅហើយ ហើយវាកាន់តែពិបាកនៅពេលដែលចំនួនមនុស្សកាន់តែកើនឡើងនៅខេត្តមណ្ឌលគិរីនេះ ដោយសារតែប្រជាពលរដ្ឋទូទៅ គេពូកែជាងជនជាតិក្នុងការរកកម្រៃ។ ហេតុនេះគាត់ត្រូវប្តូរឥរិយាបថក្នុងការប្រកបមុខរបររកស៊ុី និងរស់នៅ។ ក្នុងនោះប្រឹងរស់ដើម្បីចិញ្ចឹមកូនៗ ជាពិសេសឱ្យពួកគេខិខំរៀនសូត្រឱ្យចេះដឹង និងមានជំនាញ ទើបអាចរស់បានស្រួលនៅលើទឹកដីជនជាតិ នាសម័យបច្ចុប្បន្ននេះ។

កុមារា លី ម៉ិច អាយុ ៩ឆ្នាំ និងកុមារីលី នាងស្រី អាយុ ១១ឆ្នាំ កំពុងរៀនថ្នាក់ទី១ និងទី២ នៃសាលាបឋមសិក្សាង៉ាកែ ឃុំរម្យនា។ ពួកគេខំរៀនដែរ ប៉ុន្តែពុំសូវពូកែប៉ុន្មានទេ។ កុមារជនជាតិពីរនាក់និយាយថា នៅថ្ងៃសម្រាកពីការសិក្សា ពួកគេត្រូវស្ពាយកាផាដាក់បន្លែដាំ និងបន្លែព្រៃ ដូចជាត្រកួន ត្រសក់ ល្ពៅ ស្លឹកគ្រៃ ននោងជី ដើមចេកព្រៃ ផ្លែឈើព្រៃ ទំពាំង ដែលត្រូវធ្វើដំណើរជិត៧គីឡូម៉ែត្រ មកលក់តាមផ្ទះ និងលក់នៅផ្សារសែនមនោ-រម្យ។

លោកទឹម សង្វាត ប្រធានអប់រំខេត្តមណ្ឌលគិរី ធ្លាប់បាននិយាយថាមានអង្គការជាច្រើនដែរ ដែលសហការជាមួយក្រសួងអប់រំដើម្បីបណ្តុះបណ្តាលកុមារជន-ជាតិនៅខេត្តមណ្ឌលគិរី។ ក្រសួងអប់រំក៏បានលើកទឹកចិត្តជាពិសេស ដើម្បីឱ្យកូនចៅជនជាតិជំនាន់ថ្មីមានចំណេះដឹង ដូចកូនចៅរបស់ប្រជាពលរដ្ឋទូទៅនៅតំបន់វាលរាបផងដែរ។

គួរកត់សំគាល់ថានៅប្រទេសកម្ពុជាយើងមានជនជាតិជាច្រើនដែលរស់នៅចំរុះគ្នា ដែលក្នុងនោះជនជាតិភាគតិចនៅតំបន់ឦសាននៃប្រទេស ដែលត្រូវបានចាត់ទុកជាជនជាតិដើមរបស់ខ្មែរហើយត្រូវបានយកចិត្តទុកដាក់ពីរាជរដ្ឋាភិបាលផងដែរ នោះមានជនជាតិព្នង គួយ សំរ៉ែ...។ ដោយស្ថានភាពភូមិសាស្ត្រស្ថិតនៅជនបទដាច់ស្រយាល ពិបាកផ្លូវគមនាគមន៍ និងខ្វះហេដ្ឋារចនាសម្ព័ន្ធសេវាសង្គមផ្សេងទៀត គួបផ្សំជាមួយនឹងការប្រកាន់យកនូវទំនៀមទំលាប់ប្រពៃណីជាជនជាតិដើមរបស់ខ្លួន ក្រុមជនជាតិទាំងនេះ នៅមិនទាន់ទទួលបាននូវភាពសមរម្យនៅក្នុងការរស់នៅ នៅឡើយទេប្រសិនបើប្រៀបធៀបទៅនឹងការរស់នៅរបស់ប្រជាពលរដ្ឋខ្មែរយើង។

**កត្តាដូចបានរៀបរាប់មកខាងលើនេះ អាចជាទល្លីករណ៍ និងសុចនករមួយដ៏សំខាន់ ដែលរាជរដ្ឋាភិបាលកម្ពុជាយើងគួរតែជំរុញអោយបានខ្លាំងក្លាថែមទៀត នៅក្នុងយុទ្ធសាស្ត្រអភិវឌ្ឍន៍របស់ខ្លួន ដើម្បីជួយលើកស្ទួយស្ថានភាពរស់នៅ និងកំរិតជីវភាពរបស់ជនជាតិភាគតិច ជាពិសេសផ្តោតជាអាទិភាពលើវិស័យអប់រំ សេវាកម្មផ្នែកសុខមាលភាព កសិកម្ម និងការផ្តល់នូវសិទ្ធិជាពិសេសដល់យុវសិស្សជនជាតិ ដើម្បីទទួលបាននូវអាហាររូបករណ៍សំរាប់សិក្សានៅតាមមហាវិទ្យាល័យនានា។**

# ជីវិត និងសង្គម

## ជំហានគំរូមួយដើម្បីលុបបំបាត់អំពើរំលោភសេពសន្ថវៈ នៅប្រទេសកម្ពុជានាពេលបច្ចុប្បន្ន

**ដូចដែលយើងបានដឹងគ្រប់ៗគ្នា នូវអំពើរំលោភសេពសន្ថវៈដែលបាន និងកំពុងកើតមានឡើងជាញឹកញាប់ នៅក្នុងសង្គមខ្មែរបច្ចុប្បន្ន ជាពិសេសនៅតាមជនបទស្រុកស្រែចំការ ដែលរួមមានទាំងក្មេងស្ទាវ រឺរ័យចំណាស់រហូតដល់ធ្វើជាជីតាជីតា តួតគេបានហើយនៅតែហ៊ានប្រព្រឹត្តិដោយ ឥតខ្មាសអៀន។ រីឯជនរងគ្រោះវិញ គឺភាគច្រើនលើសលប់ ជាក្មេងស្រីមិនទាន់គ្រប់អាយុរៀបការ។**

**មានកត្តាជាច្រើន ដែលនាំអោយមានអំពើទាំងនេះ កើតឡើងមិនចេះចប់ ដែលទាំងនោះ គឺភាពអវិជ្ជារបស់ប្រជាពលរដ្ឋខ្មែរ ការហូរចូលនូវវប្បធម៌បរទេសដែលផ្ទុយពីប្រពៃណីខ្មែរ ការបញ្ចាំងភាពយន្ត និងរូបភាពអាសអាភាស និទណ្ឌភាពជាដើម។ ដូច្នេះដើម្បីទប់ស្កាត់អំពើរំលោភនេះអោយបានជាអតិបរិមា វិធានការក្តៅនានា ដែលក្នុងនោះការកាត់ទោសអោយបានត្រឹមត្រូវសមទៅនឹងទំហំនៃអំពើដែលជនលាមកទាំងនោះបានប្រព្រឹត្តិមកលើ ជនរងគ្រោះ ហើយដែលធ្វើអោយខូចដល់ប្រពៃណីខ្មែរទៀតផង។** ជាករណីគំរូមួយដែលតុលាការខេត្តកំពង់ឆ្នាំងបានកាត់ទោសជនល្មើសដែលបានចាប់រំលោភក្មេងស្រីអោយជាប់ពន្ធនាគាររយៈពេល ៧៥ឆ្នាំ និងសងជំងឺចិត្តដល់ជនរងគ្រោះចំនួន ១០ លានរៀលទៀតផង។ បន្ទាប់ពីរកឃើញថាយុវជនរូបនេះបានគំរាមចាប់រំលោភសេពសន្ថវៈទៅលើកុមារីរហូតដល់ទៅ៥នាក់នៅក្នុងភូមិជាមួយគ្នា ហើយបានសម្រេចជាច្រើនដង។

តាមការចេញផ្សាយរបស់កាសែតកម្ពុជាថ្ងៃទី ២១ ខែវិច្ឆិកា ឆ្នាំ២០០៦ បានអោយដឹងថា កាលពីថ្ងៃទី ១ខែ កក្កដា ឆ្នាំ២០០៦ កម្លាំងប៉ូលីសការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃស្នងការដ្ឋាននគរបាលខេត្តកំពង់ឆ្នាំង បានធ្វើឃាត់ខ្លួនយុវជនម្នាក់ឈ្មោះ ប៊ិច ប៊ូ អាយុ ២៤ ឆ្នាំ មានទីលំនៅឃុំតាជេស ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ដោយចោទប្រកាន់ពីបទបានគំរាមចាប់រំលោភសេពសន្ថវៈទៅលើកុមារី ចំនួន ៥នាក់ នៅក្នុងភូមិជាមួយគ្នា។ ហើយបានកសាងសំណុំរឿងបញ្ជូនខ្លួនទៅឱ្យតុលាការចាត់កាបន្តទៅតាមនីតិវិធីច្បាប់។

កាលនោះជនជាប់ចោទ ឈ្មោះ ប៊ិច ប៊ូ បានឆ្លើយសារភាពប្រាប់ប៉ូលីសថាខ្លួនគេ ពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់នេះមែន ដែលក្នុងនោះកុមារីឈ្មោះ ស.ភ.ន. អាយុ១២ឆ្នាំ គេគំរាមចាប់រំលោភបានសម្រេចចំនួន ៤ដង កុមារីឈ្មោះ ត.វ.ធ អាយុ១១ឆ្នាំ គេគំរាមចាប់រំលោភបានសម្រេចចំនួន ៣ដង កុមារីឈ្មោះ ត.ទ អាយុ៨ឆ្នាំ គេគំរាមចាប់រំលោភបានសម្រេច ចំនួន២ដង កុមារីឈ្មោះ ត.ស.ម អាយុ ៩ឆ្នាំ គេគំរាមចាប់រំលោភ ដោយយកម្រាមដៃលូកលេងប្រដាប់ភេទក្មេងស្រីនេះបានចំនួន ២ដង និងកុមារីឈ្មោះ រ.ម.ក អាយុ៤ឆ្នាំ រូបគេបានយកម្រាមដៃរុកលេងក្នុងប្រដាប់ភេទរបស់នាងបានម្តង។

លោកស្រីវរសេនីយ៍ត្រីប្រាក់ សៅនីយី នាយការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជនបានឱ្យដឹងថា សមត្ថកិច្ចបានកសាងសំណុំរឿងនេះ ជាប្រាំករណីផ្សេងៗពីគ្នា ដោយចោទប្រកាន់ឈ្មោះ ប៊ិច ប៊ូ ពីបទរំលោភសេពសន្ថវៈ និងប្រព្រឹត្តអំពើអនាចារលើកុមារី ស្ថិតក្នុងវ័យអនីតិជន។

**តាមប្រភពពីអង្គសវនាការបានឱ្យដឹងថាជនឈ្មោះ ប៊ិច ប៊ូ បានឆ្លើយសារភាពនូវអ្វីដែលគេបានប្រព្រឹត្ត ដូចដែលចម្លើយសារភាពនៅកន្លែងប៉ូលីស ហើយតុលាការបានសម្រេចផ្តន្ទាទោសក្នុងករណីនីមួយៗដោយកំណត់ដាក់គុកមួយករណីរយៈពេល១៥ឆ្នាំ និងសងជំងឺចិត្តទៅឱ្យជនរងគ្រោះក្នុងម្នាក់ៗចំនួន ២លានរៀល ដែលសរុបទាំង៥ករណី ប៊ិច ប៊ូ ត្រូវជាប់គុក ៧៥ឆ្នាំ និងសងជំងឺចិត្តទៅឱ្យជនរងគ្រោះចំនួន ១០លានរៀល។**

**ពតិមានសំខាន់សំរាប់អ្នក ជឿជាក់ថាប្រសិនបើការកាត់ទោសធ្វើឡើងដោយម៉ឺងម៉ាត់ដូចករណីមួយនេះ និងមានការសហការពីប៉ូលីសមានសមត្ថកិច្ចផងទៀតនោះ ករណីរំលោភសេពសន្ថវៈនឹងកាត់បន្ថយបានជាអតិបរមា។**

# ទំព័រចុងក្រោយសំរាប់អ្នក

## សូមបោះឆ្នោតជូនប្រាសាទអង្គរវត្តជាអច្ឆរិយទាំង៧ក្នុងពិភពលោក

វាជាមោទនភាពពន់ពេកណាស់ ដែលយើងកើតជាកូនខ្មែរលើកទឹកដីខ្មែរ ដែលសំបូរទៅដោយសម្បត្តិធម្មជាតិ និង តំលៃសិល្បៈវប្បធម៌ដ៏សំបូរបែប ហើយ ដែលនៅលើពិភពលោកបានកោតស្ញប់ស្ញែង ទទួលស្គាល់ពីស្នាដៃដ៏អសច្ចារ្យ ដែលបុព្វបុរសខ្មែរសម័យដើមបានបន្សល់ទុករហូតដល់សព្វថ្ងៃ។ ជាក់ស្តែងប្រាង្គប្រាសាទដ៏ល្អប្រណិតដែលមានក្បូរក្បាច់រចនាដ៏រស់រវើក បង្កប់ទៅដោយអត្ថន័យប្រវត្តិសាស្ត្រដ៏ផូរផង់ បាន និងកំពុងដក់ជាប់ជានិច្ចនៅក្នុងអារម្មណ៏ប្រជាពលរដ្ឋខ្មែរទាំងនៅក្នុង និង ក្រៅប្រទេស ថែមទាំងប្រជាជននានានៅលើពិលោកយើងនេះទៀតផង នោះគឺ **ប្រាសាទអង្គរវត្ត**។

នាពេលបច្ចុប្បន្ននេះ ប្រាសាទអង្គរវត្តនៃប្រទេសកម្ពុជា ជាបេក្ខភាពមួយក្នុងចំណោមបេក្ខភាព នៃបេតិកភណ្ឌមួយចំនួន ត្រូវបានប្រកាសជាបេក្ខភាពអច្ឆរិយ-វត្ថុទាំង៧ក្នុងពិភពលោក ហើយដែលការប្រកាសទទួលស្គាល់បេក្ខភាពប្រាសាទអង្គរវត្តជាអច្ឆរិយវត្ថុទាំង៧ក្នុងលោកនេះ បានប្រព្រឹត្តឡើងក្នុងពិធីទទួលស្វាគមន៍ដំណើរទស្សនាចរវាយតំលៃអច្ឆរិយវត្ថុទាំង៧ថ្មី (NEW 7 WONDER TEAM ) ដែលបានប្រារព្ធឡើងកាលពីរសៀលថ្ងៃទី ២៨ ខែវិច្ឆិកា ឆ្នាំ២០០៦ នៅរានហាលនៃរួតទីពីរប្រាសាទអង្គរវត្ត។

យោងតាមការឱ្យដឹងពីមន្ត្រីជាន់ខ្ពស់អាជ្ញាធរអប្សារា បានអោយដឹងថា ដំបូងឡើយមានបេតិកភណ្ឌពិភពលោកចំនួន១៨៧ប្រទេស បានចូលរួមការប្រកួតស្នាដៃអច្ឆរិយវត្ថុទាំង៧ក្នុងលោកនេះ។ ការបោះឆ្នោតជំរុះជំទី១ នៅសល់១១០ ប្រទេស និងជុំទី២ នៅសល់២១ប្រទេស ដែលក្នុងនោះប្រាសាទអង្គរវត្ត នៃប្រទេសកម្ពុជាស្ថិតនៅបេក្ខភាពនោះដែរ ហើយការបោះសំរេចនៅជុំទី៣ នឹងជុំរុះយកតែ៧ទេ ដែលជាអច្ឆរិយវត្ថុលើលោក ហើយដែលនឹងប្រកាសលទ្ធផលនៅថ្ងៃទី៧ កក្កដាឆ្នាំ ២០០៧ នាពេលខាងមុខឆាប់ៗនេះ។ ការជ្រើសរើសបេតិកភណ្ឌជាអច្ឆរិយវត្ថុទាំងលើលោកយើងនេះ ធ្វើឡើងដោយអង្គការពិភពលោក ដែលមានទីស្នាក់ធំនៅប្រទេសស្វីស។

**លោកស៊ូ ភីរិន្ទ អភិបាលខេត្តសៀមរាប បានអំពាវនាវនាឱកាសនេះ សូមអោយប្រជាជនកម្ពុជា ក៏ដូចប្រជាជនទូទាំងពិភពលោកជួយបោះឆ្នោទគាំទ្រដល់បេក្ខភាពប្រាសាទអង្គរវត្តជាបន្តទៀត ដើម្បីឱ្យក្លាយជាអច្ឆរិយវត្ថុទាំង៧ ក្នុងលោកពិតប្រាកដ។ លោកស៊ូ ភីរិន្ទ បានបញ្ជាក់ថា រហូតដល់បំណាច់ខែមិថុនាឆ្នាំ២០០៧ ហើយនៅថ្ងៃទី៧កក្កដា ឆ្នាំ ២០០៧ នឹងប្រកាសលទ្ធលជ្លូវការនូវបេតិកភណ្ឌ ចំនួន ៧ ដែលត្រូវក្លាយជាអច្ឆរិយវត្ថុទាំង៧នៅ លើលោកយើងនេះ។ ការបោះឆ្នោតត្រូវបោះតាមប្រព័ន្ធ Internet ដែលមានអាស័យដ្ឋាន www.new7wonders.com ។**

គួរបញ្ជាក់ថា កាលពីរសៀលថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០០៦ ខេត្តសៀមរាប បានទទួលរៀបចំស្វាគមន៏ដំណើរទស្សនាចរវាយតំលៃអច្ឆរិយវត្ថុទាំង៧ ថ្មី (NEW 7 WONDER TEAM) រានហាល នៃរួតទីប្រាសាទអង្គរវត្តដែលដឹកនាំដោយលោក ស៊ូ ភីរិន្ទ អភិបាលខេត្តសៀមរាប លោក ប៊ុន ណារិទ្ធ ប្រធានអគ្គនាយកអជ្ញាធរអប្សារា ហើយក្នុងពិធីនោះលោក BERNARD WEBER ប្រធានក្រុមដឹកនាំការងារ NEW 7 WONDERS បានប្រកាសប្រាសាទអង្គរវត្តជាបេក្ខភាពអច្ឆរិ-យវត្ថុទាំង៧នៅលើលោក និងប្រគល់វិញ្ញាប័នបត្របញ្ជាក់ផងដែរដល់អភិបាលខេត្ត។ ជូនដល់ចៅហ្វាយខេត្តសៀមរាប ។

**សូមបោះឆ្នោតជូនប្រាសាទអង្គរវត្តជាអច្ឆរិយទាំង៧ ក្នុងពិភពលោក !!!**

**សូមផ្ញើរមតិរបស់អ្នកមកកាន់យើងខ្ញុំដើម្បីចុះផ្សាយ**

**Email:** ard.info@yahoo.com